**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ១៤ រោច ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងារ រវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ ឯកឧត្តម Pablo Chiho Kang ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលី

នៅព្រឹកថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Pablo Kang ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាអំពីទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍថ្មីនៃកម្មវិធីភាពជាដៃគូរវាងកម្ពុជា និងអូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ។

ក្នុងឱកាសនោះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលអូស្ត្រាលីដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ហិរញ្ញប្បទានឥតសំណងដល់កម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ និងផ្តល់ការឧបត្ថម្ភជាវ៉ាក់សាំង និងសម្ភារៈសុខាភិបាល ដើម្បីចូលរួមចំណែកក្នុងការទប់ស្កាត់ការរីករាលដាល់នៃជំងឺកូវីដ-១៩ នៅកម្ពុជា ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានសង្កត់ធ្ងន់ថា អូស្ត្រាលីតែងតែផ្តល់ការគាំទ្រដល់កម្ពុជា ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈការផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ លើវិស័យសំខាន់ៗជាច្រើន ជាពិសេស វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ អប់រំ ថាមពល ។ល។

ឯកឧត្តមឯកអគ្គរាជទូតអូស្ត្រាលី Pablo Kang បានគូសបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ និងយូរអង្វែងមកហើយ រវាងរាជរដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា ហើយឆ្នាំនេះជាខួបគម្រប់ទី ៧០ ឆ្នាំនៃការចាប់ផ្តើម ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ដោយឯកឧត្តមបានគូសបញ្ជាក់ថា អូស្ត្រាលីនឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួន និងបន្តផ្តល់ការគាំទ្ររបស់ខ្លួននៅកម្ពុជា ។

ជាការអបអរសាទរសម្រាប់ខួបទី ៧០ ឆ្នាំរវាងប្រទេសទាំងពីរ, ភាគីអូស្ត្រាលី តាមរយៈមូលនិធិ Department of Foreign Affairs and Trade (DFAT) គ្រោងនឹងផ្តល់កិច្ចសហប្រតិបត្តិការហិរញ្ញប្បទានឥតសំណងថ្មី ក្រោមកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់

(CAP-RED) ដែលមានទឹកប្រាក់ចំនួនប្រមាណ AUD ៨៧ លាន (ប្រមាណជាង USD ៦៥ លាន) សម្រាប់រយៈពេល ៥ ឆ្នាំដំបូង គិតចាប់ពីពាក់កណ្ដាលឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៧ និងអាចបន្តផ្ដល់បន្ថែមរហូតដល់ AUD ៥៧ លាន (ប្រមាណជាង USD ៤២ លាន) សម្រាប់រយៈពេលបន្ថែម ៣ ឆ្នាំបន្ទាប់ទៀត ដោយអាចបន្តទៅដល់ពាក់កណ្ដាលឆ្នាំ ២០៣០ ។ កម្មវិធី CAP-RED មានគោលបំណងធំៗ ៣ គឺ៖ ១.ជួយជ្រោមជ្រែងដល់កម្ពុជាក្នុងការអភិវឌ្ឍលើផ្នែកកសិកម្មដែលមានតម្លៃខ្ពស់ និងចាប់ផ្ដើមលើវិស័យកែច្នៃកសិផល; ២.សហការជាមួយរាជរដ្ឋាភិបាលកម្ពុជា លើការងារជុំវិញគោលនយោបាយពាណិជ្ជកម្ម និងវិនិយោគ ព្រមទាំងអភិវឌ្ឍន៍សហគ្រាស ដើម្បីជួយជ្រោមជ្រែងកម្ពុជាក្នុងការពង្រីកទីផ្សាររបស់ខ្លួន និងគាំទ្រអាជីវកម្មកម្ពុជា ដើម្បីលើកកម្ពស់ស្តង់ដាគុណភាពរបស់ខ្លួន ដើម្បីអាចនាំចូលទៅទីផ្សារនានា និង ៣.បន្តវិនិយោគដើម្បីពង្រីកវិស័យហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពនៅកម្ពុជា ជាពិសេស ក្នុងវិស័យទឹក ថាមពល និងភស្តុភារ ។ កម្មវិធីថ្មីនេះត្រូវបានផ្ដួចផ្ដើមឡើង និងគិតគូរយ៉ាងល្អិតល្អន់ ស្របតាមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងត្រូវបានអនុវត្ត បន្ទាប់ពីទទួលបានលទ្ធផលជោគជ័យនៃការអនុវត្តកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជាជំហានទី ១ និងទី ២ (CAVAC I & II) និងកម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

ក្នុងឱកាសនោះដែរ, ឯកឧត្តម **Pablo Kang** ក៏បានសម្ដែងនូវការកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលសម្រេចបាននូវសមិទ្ធផលផ្លែផ្កាជាច្រើន ជាពិសេស ការចាត់វិធានការយ៉ាងល្អប្រសើរក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ឯកឧត្តមបានគូសបញ្ជាក់ផងដែរថា ឯកឧត្តមនឹងបន្តខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសនឹងបន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ។

ជាទីបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាល និងប្រជាជនអូស្ត្រាលី ដែលបានជួយអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា និងសម្ដែងនូវការគាំទ្រពេញទំហឹងចំពោះការប្ដេជ្ញាផ្ដល់ហិរញ្ញប្បទានឥតសំណងបន្ថែមសម្រាប់វិធីថ្មីខាងលើនេះ ដែលនឹងជួយដល់ការអភិវឌ្ឍវិស័យកសិកម្ម កសិ-ឧស្សាហម្ម ពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា ដោយគូសបញ្ជាក់ថា ទោះបីជាពិភពលោកកំពុងស្ថិតក្នុងស្ថានភាពប្រឈមទៅនឹងជំងឺកូវីដ-១៩ ដែលប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងណាក្តី, រាជរដ្ឋាភិបាលកម្ពុជានៅតែខិតខំ និងត្រៀមលក្ខណៈជាស្រេច ក្នុងការផ្ដល់កិច្ចសហការ និងបន្តការគាំទ្រដល់កិច្ចសហប្រតិបត្តិការនានាបន្ថែមទៀត រវាងប្រទេសទាំងពីរ ដើម្បីសម្រេចបាននូវសមិទ្ធផលល្អប្រសើរថ្មីៗបន្ថែមទៀត ។